**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ
# សាមគ្គីស្ទឹងនាងសល្វាចសែនជ័យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ
# រយៈពេល ៣ ឆ្នាំ
# (២០០៨~ ២០១០)

ឈ្មោះសហគមន៍នេសាទ : សាមគ្គីស្ទឹងនាងសល្វាចសែនជ័យ
ភូមិ : នាងសល្វាច ឃុំប្រឡាយ
ភូមិ : នាងសល្វាច ឃុំកំពង់ចិនជើង
ស្រុក : ស្ទោង
ខេត្ត : កំពង់ធំ

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ **សាមគ្គីស្ទឹងនាងសល្វាចសែនជ័យ** ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅ ១១ ខែឧសភា ឆ្នាំ ២០០៧ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០០៧។

សហគមន៍នេសាទ **សាមគ្គីស្ទឹងនាងសល្វាចសែនជ័យ** មានទីតាំងស្ថិតនៅក្នុងភូមិនាងសល្វាច ឃុំកំពង់ចិនជើង និភូមិនាងសល្វាច ឃុំប្រឡាយ ស្រុកស្ទោង ខេត្តកំពង់ធំ ដែលមានសមាជិកសរុបចំនួន១៩៣នាក់ ក្នុងនោះស្ត្រីចំនួន ៧១នាក់ និងមានគណៈកម្មការសហគមន៍ចំនួន០៩នាក់ ស្រីចំនួន០១នាក់ និងមានគ្រួសារសរុបចំនួន១៦៥ គ្រួសារ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមានៈ

-ចុះឈ្មោះសមាជិកសហគមន៍ និងផ្សព្វផ្សាយពីទស្សនៈទាននៃការបង្កើតសហគមន៍នេសាទ

-បានបើកមហាសន្និបាតកំណើតដំបូង បោះឆ្នោតជ្រើសរើសគណៈកម្មការ និងបែងចែកតួនាទី ភារៈកិច្ចគណៈកម្មការសហគមន៍នេសាទ

-បានពិគ្រោះយោបល់ធ្វើលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

-បានពិគ្រោះយោបល់កំណត់ព្រំប្រទល់កន្លែងនេសាទ និងផែនទីសហគមន៍នេសាទ

-បានពិគ្រោះយោបល់ និងចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយខណ្ឌរដ្ឋបាលជលផល

-បានផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ផែនទីកន្លែងនេសាទសហគមន៍ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ។

-បានផ្សព្វផ្សាយបង្កើនការយល់ដឹងអំពី ផលប៉ះពាល់នៃការកាប់បំផ្លាញព្រៃលិចទឹក និងសារៈប្រយោជន៍ព្រៃលិចទឹក និងផ្សព្វផ្សាយច្បាប់ស្តីពីជលផល

-បានពិភាក្សារធ្វើសេចក្តីព្រាងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាជនសរុបៈ

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន១០១០នាក់ ប្រុស៣៦៥នាក់ ស្រី៦៤៥នាក់។ ក្នុងនោះមានជនជាតិខ្មែរ ១០០%។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ៥១នាក់

- ចំនួនជនពិការក្នុងសហគមន៏នេសាទ ១០នាក់ ស្រី ២នាក់
- ចំនួនចាស់ជរាក្នុងសហគមន៏នេសាទមាន ២១នាក់ ស្រី ១៧នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៏នេសាទមាន ១០នាក់ ស្រី ៤នាក់
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៏នេសាទមាន ១៩នាក់ ស្រី១៤នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៏ជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០% ។
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៏នេសាទទាំងអស់ អ្នកមិនចេះអក្សរមានចំនួន ២៧នាក់ស្រី ២៤នាក់ រៀនត្រឹមកម្រិតថ្នាក់បឋមសិក្សាចំនួន៨៦០នាក់ ស្រី៥០០នាក់ កំរិតមធ្យមសិក្សាចំនួន១៨នាក់ស្រី ៩នាក់ និងកំរិតថ្នាក់ឧត្តមសិក្សាគ្មាន ។

**ខ-មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៏រួមមាន:

- ធ្វើនេសាទចំនួន ១៧៨គ្រួសារ
- ធ្វើស្រែចំនួន ១៧៨គ្រួសារ ទំហំ ០ហិកតា
- ដាំបន្លែចំនួន គ្រួសារ ១៧០ ទំហំ ( សួនតូចៗតាមគ្រួសារ)
- ធ្វើវារីវប្បកម្មចំនួន ៣៨
- ជាងផ្ទះចំនួន០២គ្រួសារ
- ជាងធ្វើទូក១៣គ្រួសារ
- ជាងកាត់សក់២នាក់
- ជាងជួសជុលម៉ាស៊ីន ១គ្រួសារ
- បញ្ចូលអាគុយ២គ្រួសារ
- កាត់ដេរ៣គ្រួសារ
- រត់ម៉ូតូឌុប១គ្រួសារ
- ម៉ាស៊ីនកិនស្រូវ៥គ្រួសារ

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៏ **សាមគ្គីស្ទឹងនាងសល្វាចសែនជ័យ** មានទំហំសរុប៣២០ហិកតា និងមានកំណត់និយាមកា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹងតាមុំ
- ខាងត្បូងទល់នឹងកោះកៀនផ្ដៅ
- ខាងកើតទល់នឹងអូពាមត្រែង
- ខាងលិចទល់អ្នកតាប្រកៀប

**ខ. ដែននេសាទ**

កន្លែងនេសាទសហគមន៍ **សាមគ្គីស្ទឹងនាងសល្វាចសែនជ័យ** មានធនធានសំខាន់ៗរួមមាន ៖-

- ស្ទឹងនាងសល្វាច ទំហំ ១២៥,៥៨ ហិកតា នេសាទពីខែ១ ដល់ខែ១២
- ត្រពាំងតាសេង ទំហំ ១,១៩ ហិកតា នេសាទពីខែ១ ដល់ខែ១២
- ព្រៃអូរស្ពានស្រស់ ៥៤,៥៣ ហិកតា នេសាទពីខែ៦ដល់ខែ១
- ព្រៃក្របីដេក ២០,៦៣ នេសាទពីខែ៦ ដល់ខែ១២
- ព្រៃលិចទឹកព្រែកតូចខាងត្បូង៤,៤៥ ហិកតា នេសាទពីខែ៦ ដល់ខែ១
- ព្រៃលិចទឹកព្រែកតូចខាងជើង៥,៣៩ ហិកតា នេសាទពីខែ៦ ដល់ខែ១
- វាលស្មៅទំនាបលិចទឹកមាន ៣ កន្លែង ១៣,២៧ នេសាទពីខែ៧ ដល់ខែ១១

**គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

-កន្លែងអភិរក្សត្រីមេពូជ នៅចំណុចអន្លង់អភិរក្សអូរស្ពានស្រស់មួយកន្លែង ទំហំ៧,១៩ហិកតា

-កន្លែងអភិរក្សព្រៃលិចទឹក ២កន្លែង ទំហំ៧,១៩ហិកតា នៅចំណុចអូរស្ពានស្រស់លិច និង ព្រៃអភិរក្សអូរស្ពានស្រស់កើត ។

**ឃ. ធនធានជលផល**

**ប្រភេទត្រី ៖**

- ត្រីរ៉ស់-ឆ្តោរ-រៀល-ស្លាត-ឆ្លាំង-ក្អែក-កន្ធរ-កែ-អំពិលទុំ-ចង្វាមូល-ក្លាំងហាយ-ត្រីប្រា-ក្រម៉ម-អណ្តែង-ចង្វា-កំភ្លាញ-ឆ្លូញ-ក្រាញ់-ខ្ជាន់-ឆ្ពិន-ច្រកែង-កេស-គ្រុំ-ដំរី-ប្រម៉ា-កន្ទ្រប់-ដំរី-កញ្ចុះ-ក្រុស-ផ្ទោង-កញ្ចាញ់ច្រាស់-កញ្ជ្រូក-កាហែរ-កំភ្លាវ-លិញ-ត្រនេល-សណ្តាយ-ក្រាយ-ច្រឡឹង-ព្រលូង-ត្រីស្លឹកឫស្សី-ត្រីខ្ចឹង-កំពត-អន្ទង់ ។

**ប្រភេទវារីសត្វផ្សេងៗ ៖**

- ក្តាម-ខ្យង-ខ្ចៅ-គ្រុំ-លៀស-អណ្តើក-កន្ធាយ-ពស់-កំពិស-កង្កែប ។

**ប្រភេទសត្វស្លាបទឹក:**

- កុកស-កុកក្រក-មាន់ទឹក-មាន់ទោល-ទោម-ប្រវឹក-ខ្ញុំ-ទាព្រៃ-រនាលខ្យង-ក្រសា-ត្រដក់-ក្អែកទឹក-ស្មោញ-អក-អែអូត-ក្អែកគោក-ខ្វែក ។

**ប្រភេទសត្វ :**

- ស្វា-ខ្លាត្រី ចចក ។

**ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ :**

- ដើមរាំង-ភ្នំភ្លើង-អញ្ចាញ-គ្រស់-សណ្ដាន់-បបួយ-តាអូរ-ត្រឡាក-ខ្ញុំ-ល្បៀង-ទៀនព្រៃ-ថ្មើមអណ្ដើក-ខ្លាយមាន់-កណ្ដាប់ចង្កេរ-ត្រសែង-ញរ-សាច់ពៅ-ប្រផេញ-វល្លិប្រេង-ឈ្លើយ-ល្ពាក់-ផ្ដៅទឹក-វល្លិដូងព្រះ-វល្លិតាអើក-កំផ្លោក-ស្មោ-ត្រកួន ក្រជីព ត្រាវគៀត កពឹងពួយ ប្រធិញញី ប្រធិញឈ្មោល អញ្ចាញ ។ (ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធទី.........ភ្ជាប់មកជាមួយ) ។

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន១៧៨នាក់ ស្រី ៦០នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន២០០នាក់ ស្រី ១០០នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ២៥០ នាក់ ស្រី ១០០នាក់

### ខ. ឧបករណ៍នេសាទ

**- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍:**

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ, ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ.......ដល់ ខែ........) |
|---|---|---|---|---|
| មង | ត្បូង (៤០ម) | ១២៤៦ (១៧៨ន x៧) | ក្រឡា=២-២,៥-៧ហ៊ុន<br>សំរុង=១-១,៥ម<br>ប្រវែង=៤៩.៨៤០ម | ខែ០១-ខែ១២ |
| អួនហ៊ុំសំរាស់ | វង់ (១០០ម) | ៩ (៩ន x ១វង់) | ក្រឡា=១,៥-៣ហ៊ុន<br>សំរុង=៥ម<br>ប្រវែង=៩០០ម | ខែ១២-ខែ០៦ |
| សន្ទូចរនង | សាង (១០០ផ) | ៣៥០ (៧០ន x៥ស) | ផ្លែលេខ១២ | ខែ៨ -ខែ០១ |

| | | | | |
|---|---|---|---|---|
| លបបង្កប់ | គ្រឿង | ១០០<br>(៥ន x ២០គ) | ទំហំ=៣ម x0,៨ម<br>ចន្លោះគ្រៀម=២ហ៊ុន | ខែ៤-ខែ០៦ |
| លបទល់ | គ្រឿង | ១៨០<br>(៦នx៣០គ ) | ទំហំ=៣ម x១,៥ម<br>ចន្លោះគ្រៀម=២ហ៊ុន | ខែ១០-ខែ៤ |
| អញ្ចង | វង់<br>(៤០ម) | ២០<br>(២០ន x១វង់) | ទំហំ=0,៥ x 0,៦មx ៤០ម.<br>ក្រឡា=២ហ៊ុន | ខែ០១-ខែ១៥ |
| ទ្រូសាច់អួន | ឡុង<br>(៤០ម.) | ១០០<br>(១០ន x៥ឡ) | ទំហំ0,៥ម x ៨ម<br>ក្រឡា២-៤ហ៊ុន | ខែ០១-ខែ១២ |
| សំណាញ់ | វង់ | ១០<br>(១០នx១វង់) | ប្រវែង៦ម<br>ក្រឡា២,៥ម-៣ម | ខែ០១-ខែ១២ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកអុំ | ១៧៨ គ្រឿង | ២០០-៣០០គក្រ | |
| កាណូត | ១០០គ្រឿង | ១០០០-២០០០គក្រ | ៥,៥-១៣០សេះ |

**- ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ :**

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ, ប្រវែង | រដូវប្រើប្រាស់ឧបករណ៍<br>(ខែ.......ដល់ ខែ........) |
|---|---|---|---|---|
| មង | ត្បូង<br>(៤០ម) | ១២៤៦<br>(១៧៨ន x៧) | ក្រឡា=២-២,៥-៧ហ៊ុន<br>សំរុង=១-១,៥ម<br>ប្រវែង=៤៩.៨៤០ម | ខែ០១-ខែ១២ |
| អួនហ៊ុំសំរាស់ | វង់<br>(១០០ម) | ៩<br>(៩ន x ១វង់) | ក្រឡា=១,៥-៣ហ៊ុន<br>សំរុង=៥ម<br>ប្រវែង=៩០០ម | ខែ១២-ខែ០៦ |
| សន្ទូចរនង | សាង<br>(១០០ផ) | ៣៥០<br>(៧០ន x៥ស) | ផ្លែលេខ១២ | ខែ៨ -ខែ០១ |

| | | | | |
|---|---|---|---|---|
| លបបង្កប់ | គ្រឿង | ១០០<br>(៥ន x ២០គ) | ទំហំ=៣ម x០,៨ម<br>ចន្លោះត្រៀម=២ហ៊ុន | ខែ៤-ខែ០៦ |
| លបទល់ | គ្រឿង | ១៨០<br>(៦នx៣០គ ) | ទំហំ=៣ម x១,៥ម<br>ចន្លោះត្រៀម=២ហ៊ុន | ខែ១០-ខែ៤ |
| អញ្ចង | វង់<br>(៤០ម) | ២០<br>(២០ន x១វង់) | ទំហំ=០,៥ x ០,៦មx ៤០ម.<br>ក្រឡា=២ហ៊ុន | ខែ០១-ខែ១៥ |
| ទ្រូសាច់អួន | ឡុង<br>(៤០ម.) | ១០០<br>(១០ន x៥ឡ) | ទំហំ០,៥ម x ៨ម<br>ក្រឡា២-៤ហ៊ុន | ខែ០១-ខែ១២ |
| សំណាញ់ | វង់ | ១០<br>(១០នx១វង់) | ប្រវែង៦ម<br>ក្រឡា២,៥ម-៣ម | ខែ០១-ខែ១២ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកអុំ | ១៧៨ គ្រឿង | ២០០-៣០០គក្រ | |
| កាណូត | ១០០គ្រឿង | ១០០០-២០០០គក្រ | ៥,៥-១៣០សេះ |

**- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ :**

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ, ប្រវែង | រដូវប្រើប្រាស់ឧបករណ៍<br>(ខែ.......ដល់ ខែ........) |
|---|---|---|---|---|
| មង | ត្បូង<br>(៤០ម) | ២៥០<br>(៥០ន x៥ ) | ក្រឡា=២-២,៥-៧ហ៊ុន<br>សំរុង=១-១,៥ម<br>ប្រវែង=១០.០០០ម | ខែ០១-ខែ១២ |
| សន្ទូចរនង | សាង<br>(១០០ផ) | ៣០០<br>(៣០ន x១០ស) | ផ្លែលេខ១២ | ខែ៨ -ខែ០១ |
| លបទល់ | គ្រឿង | ១៨០<br>(១០នx៤០គ ) | ទំហំ=៣ម x១,៥ម<br>ចន្លោះត្រៀម=២ហ៊ុន | ខែ១០-ខែ៤ |
| ឆក់ | គ្រឿង | ១០ | | ខែ០១២-ខែ៤ |

| | | | | |
|---|---|---|---|---|
| | | (១០ន x១គ) | | |
| គាង | គ្រឿង | ១០<br>(១០ន x១) | | ខែ០២-ខែ៣ |
| សំណាញ់ | វង់ | ២០<br>(២០នx១វង់) | ប្រវែង៦ម<br>ក្រឡា២,៥ម-៣ម | ខែ៣-ខែ៤ |
| ខ្នោសត្រី | គ្រឿង | ៥<br>(៥នx១គ) | មុខ 0,៥ម. | ខែ៣-ខែ៤ |
| អង្រុត | គ្រឿង | ៥០<br>(៥០នx១គ) | | ខែ៣-ខែ៤ |
| ស្ន | គ្រឿង | ២<br>(២នx១គ) | | ខែ៣-ខែ៤ |
| ឆ្នុកដៃ | គ្រឿង | ១០<br>(១០នx១គ) | ក្រឡា៣ហ៊ុន | ខែ៣-ខែ៤ |

| **ប្រភេទទូក កាណូត** | **ចំនួន** | **ចំណុះ** | **កំលាំងសេះ** |
|---|---|---|---|
| ទូកអុំ | គ្មាន | | |
| កាណូត | គ្មាន | | |

## គ. ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ *(គិតជា គក)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៨០ គក្រ | ៤០ គក្រ | ១២០ គក្រ |
| ក្តាម ខ្យង | | ៥ គក្រ | ៥ គក្រ |

125 Kg

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

សហគមន៍នេសាទ **សាមគ្គីស្ទឹងនាងសល្វាចសែនជ័យ** មានទស្សនៈវិស័យរួម គឺចូលរួមគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកប ដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

### ខ. គោលបំណងរួម

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប ជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ និងនាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព ធ្វើឱ្យធនធានធម្មជាតិក្នុងតំបន់បានសម្បូរឡើងវិញ និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

**គោលបំណង:**

- គ្រប់គ្រងធនធានជលផលឱ្យបានសមស្រប និងធ្វើឱ្យប្រសើរឡើងវិញនូវធនធានជលផលនៅក្នុងកន្លែងនេសាទសហគមន៍
- កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ និងកាត់បន្ថយទំនាស់នៅក្នុងកន្លែងនេសាទសហគមន៍
- បង្កើនការយល់ដឹងពីការគ្រប់គ្រងធនធានជលផលនៅក្នុងតំបន់គ្រប់គ្រងដោយសន.

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវកាលនេសាទ។ ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន(ក្នុង១ថ្ងៃ) | |

| | | | | | |
|---|---|---|---|---|---|
| ស្ទឹងនាងសល្វាច | ខែ១-១២ | មង | ក្រឡា=២,៥ហ៊ុនឡើង<br>ប្រវែង=១.៥០០ម | ១០ន | ១ន=១៥០ម |
| | ខែ១-១២ | លបទុល | ទំហំ=៣ម ខ១,៥ម<br>ចន្លោះត្រៀម=២ហ៊ុន<br>ចំនួន១៨០គ្រឿង | ៦ន | ១ន=៣០គ |
| | ខែ១-១២ | សន្ទូច | ផ្លែលេខ១២-១៤<br>ចំនួន=១៥.០០០ផ | ៥០ន | ១ន=៣០០ផ |
| | ខែ១-១២ | លបបង្កប់ | ទំហំ=៣ម x០,៨ម<br>ចន្លោះត្រៀម=២ហ៊ុន<br>ចំនួន៦០គ្រឿង | ៣ន | ១ន=២០គ |
| | ខែ១-១២ | អួន | ទំហំ=០,៥x០,៦ម<br>ក្រឡា=២-៣ហ៊ុន<br>ចំនួន១០វង់=១០០០ម. | ១០ន | ១ន=១វង់ |
| | ខែ១-១២ | សំណាញ់ | ប្រវែង ៦ម.<br>ក្រឡា=២-៣ហ៊ុន<br>ចំនួន៣០វង់ | ៣ន | ១ន=១វង់ |
| | ខែ១-១២ | អញ្ចង | ក្រឡា=២ហ៊ុន<br>ចំនួន៥វង់=២០០ម. | ៥ន | ១ន=១វង់ |
| | ខែ១-១២ | ទ្រូសាច់អួន | ចំនួន២៥គ្រឿង | ៥ន | ១ន=៥គ |
| -អូរពាមត្រែង<br>-អូរស្ពានស្រល់<br>-អូរអន្លុងក្រម៉ាល់ | ខែ០៦-០២ | មង | ក្រឡា=២,៥-៤ហ៊ុន<br>ប្រវែង=១.៥០០ម | ១០ន | ១ន=១៥០ម |
| | ខែ០៦-០២ | សន្ទូច | ផ្លែលេខ ០៥-១២<br>ចំនួន=៥០០ផ | ៥ន | ១ន=១០០ផ |
| | ខែ០៦-០២ | លបបង្កប់ | ចំនួន=២០គ្រឿង | ១ន | ១ន=២០គ |
| | ខែ០៦-០២ | សំណាញ់ | ប្រវែង ៦ម.<br>ក្រឡា=២-៣ហ៊ុន<br>ចំនួន១វង់ | ១ន | ១ន=១វង់ |
| | ខែ០៦-០២ | អញ្ចង | ក្រឡា=២ហ៊ុន<br>ចំនួន១វង់=៤០ម. | ១ន | ១ន=១វង់ |

| | | | | | |
|---|---|---|---|---|---|
| | ខែ០៦-០២ | ទ្រូសាច់អួន | ចំនួន=១០គ្រឿង | ២ន | ១ន=៥គ |
| | ខែ០៦-០២ | មង | ក្រឡា=២,៥-៤ហ៊ុន<br>ប្រវែង=១.៥០០ម | ១០ន | ១ន=១៥០ម |
| | ខែ០៦-០២ | សន្ទូច | ផ្លែលេខ ០៥-១២<br>ចំនួន=២០០ផ | ២ន | ១ន=១០០ផ |
| | ខែ០៦-០២ | លបបង្កប់ | ចំនួន=៤០គ្រឿង | ២ន | ១ន=២០គ |
| ត្រពាំងអណ្ដើក | ខែ០៦-០២ | សំណាញ់ | ប្រវែង ៦ម.<br>ក្រឡា=២-៣ហ៊ុន<br>ចំនួន១វង់ | ១ន | ១ន=១វង់ |
| | ខែ០៦-០២ | អញ្ចង | ក្រឡា=២ហ៊ុន<br>ចំនួន១វង់=៤០ម. | ១ន | ១ន=១វង់ |
| | ខែ០៦-០២ | ទ្រូសាច់អួន | ចំនួន=៥គ្រឿង | ១ន | ១ន=៥គ |
| | ខែ០៦-០២ | លបទុល | ទំហំ=៣ម x១,៥ម<br>ចន្លោះត្រែម=២ហ៊ុន<br>ចំនួន២០គ្រឿង | ២ន | ១ន=១០គ |
| | ខែ០៦-០២ | លបបង្កប់ | ចំនួន=៤០គ្រឿង | ១ន | ១ន=១០គ |
| ត្រពាំងតាអូរក្នុង<br>ត្រពាំងតាអូរក្រៅ | ខែ០៦-០២ | សំណាញ់ | ប្រវែង ៦ម.<br>ក្រឡា=២-៣ហ៊ុន<br>ចំនួន១វង់ | ១ន | ១ន=១វង់ |
| | ខែ០៦-០២ | អញ្ចង | ក្រឡា=២ហ៊ុន<br>ចំនួន១វង់=៤០ម. | ១ន | ១ន=១វង់ |
| ត្រពាំងអកនាង | ខែ០៦-០២ | មង | ក្រឡា=២,៥-៤ហ៊ុន<br>ប្រវែង=៣០០ម | ២ន | ១ន=១៥០ម |
| | ខែ០៦-០២ | សន្ទូច | ផ្លែលេខ ០៥-១២<br>ចំនួន=២០០ផ | ២ន | ១ន=១០០ផ |
| | ខែ០៦-០២ | លបបង្កប់ | ចំនួន=១០គ្រឿង | ១ន | ១ន=១០គ |
| | ខែ០៦-០២ | សំណាញ់ | ប្រវែង ៦ម.<br>ក្រឡា=២-៣ហ៊ុន<br>ចំនួន១វង់ | ១ន | ១ន=១វង់ |

| | | | | | |
|---|---|---|---|---|---|
| | ខែ០៦-០២ | អញ្ចង | ក្រឡា=២ហ៊ុន ចំនួន១វង់=៤០ម. | ១ន | ១ន=១វង់ |
| | ខែ០៦-០២ | ទ្រូសាច់អួន | ចំនួន=៥គ្រឿង | ១ន | ១ន=៥គ |
| ត្រពាំងជូនអុក | ខែ០៦-០២ | លបបង្គប់ | ចំនួន=១០គ្រឿង | ១ន | ១ន=១០គ |
| | ខែ០៦-០២ | អញ្ចង | ក្រឡា=២ហ៊ុន ចំនួន១វង់=៤០ម. | ១ន | ១ន=១វង់ |

## គ.២ ផែនការកែលំអផែននេសាទ

**គោលបំណង**

- រក្សាបាននូវនិរន្តរភាពនៃផលត្រីនៅក្នុងធម្មជាតិ និងរក្សាបាននូវសុវត្ថិភាពស្បៀងសំរាប់សហគមន៍
- បង្កើតជាទីជំរក និងការលូតលាស់របស់ត្រី
- ធ្វើឱ្យប្រសើរឡើងនូវកន្លែងនេសាទសំរាប់ចរាចរណ៍ និងការស៊ីចំណី ។

| ឈ្មោះកន្លែងនេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ស្តារព្រែក អន្លង់អភិរក្ស អូរស្ពានស្រល់ | ៧,១៥ ហិកតា | ១,៦២ ហិកតា | ស្តារមមោកបាតព្រែកដោយប្រើគ្រឿងចក្រ | មេសា ២០០៨ | ឧសភា ២០០៨ | សុំជំនួយពី NGOs ឬរដ្ឋាភិបាល |

## គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

**គោលបំណង**

- បង្កើនពូជត្រី ឬស្តុកត្រី និងសត្វគ្រប់ប្រភេទ
- ថែរក្សា ការពារព្រៃលិចទឹកនៅជុំវិញ ដែលជាជំរក និងជាប្រភពចំណីធម្មជាតិ
- ផ្សព្វផ្សាយ និងផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋឱ្យចេះស្រឡាញ់ធនធានធម្មជាតិ
- កាត់បន្ថយការនេសាទល្មើសច្បាប់ ។

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| អន្លង់អភិរក្សអូរស្ពានស្រស់ | ៧.១៩ហាត. | -ពូជត្រីគ្រប់ប្រភេទ<br>-សត្វគ្រប់ប្រភេទ | -កំណត់ព្រំប្រទល់កន្លែងអភិរក្ស<br>-បោះបង្គោល ដាក់ស្លាកសញ្ញាហាមឃាត់<br>-ដាក់ជំរកត្រីសិប្បនិម្មិត<br>-រៀបចំរោងយាបល្បាត និងយាមល្បាតជាប្រចាំ។ | ២០០៨ | ២០១០ | រកដៃគូ NGOs និង រដ្ឋាភិបាលជួយ |
| -ព្រៃអភិរក្សអូរស្ពានស្រស់លិច<br>-ព្រៃអភិរក្សអូរស្ពានស្រស់កើត | ២៥.៥៦ហាត.<br><br>៤.១៤ហាត. | -អភិរក្សព្រៃលិចទឹកគ្រប់ប្រភេទ<br>-សត្វគ្រប់ប្រភេទ | -កំណត់ទីតាំងកន្លែងអភិរក្ស<br>-បោះបង្គោលព្រំប្រទល់ និងស្លាកសញ្ញាហាមឃាត់<br>-ឃ្លាំមើល តាមដានត្រួតពិនិត្យជាប្រចាំ។ | ២០០៨ | ២០១០ | រកដៃគូ NGOs និង រដ្ឋាភិបាលជួយ |

## គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

### គោលបំណង

- គ្រប់គ្រងព្រៃលិចទឹកឱ្យនៅគង់វង្ស និងបានប្រសើរឡើងវិញ
- ផ្តល់ឱកាស និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងការគ្រប់គ្រងធនធានធម្មជាតិ
- កាត់បន្ថយការកាប់បំផ្លាញ និងប្រើប្រាស់ព្រៃលិចទឹកក្នុងតំបន់គ្រប់គ្រងដោយសហគមន៍។

គ.៤.១.ផែនការគ្រប់គ្រង និងថែរក្សាព្រៃលិចទឹក

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទព្រៃដែលត្រូវការពារ និងថែរក្សា | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|

| | | | | | | |
|---|---|---|---|---|---|---|
| -កន្លែងដាំព្រៃលិច ទឹកឡើងវិញ នៅចំណុចប៉ោយតាមិញ<br><br>-កន្លែងដាំព្រៃលិចទឹកឡើងវិញ នៅចំណុចចំការតាសាត | ១,១១ ហិកតា<br><br>០,៨៨ ហិកតា | ព្រៃលិចទឹកគ្រប់ប្រភេទ | -ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃព្រៃលិចទឹក<br>-ដាក់ស្លាកសញ្ញាហាមការកាប់ព្រៃលិចទឹក<br>-បែងចែកក្រុមដើម្បីល្បាតការពារព្រៃលិចទឹក<br>-អនុវត្តតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ ក្នុងករណីមានការល្មើសកាប់ ឬបំផ្លាញព្រៃលិចទឹក។ | ២០០៨ | ២០១០ | សុំជំនួយជាសំភារៈ និងថវិកាក្នុងការល្បាតឃ្លាំមើលព្រៃលិចទឹក |

## គ.៥ ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

**គោលបំណង**

- បង្កើនប្រាក់ចំណូលក្នុងគ្រួសារសមាជិកសហគមន៍
- កាត់បន្ថយការចាប់ត្រីពីក្នុងធម្មជាតិ ឬក្នុងដែននេសាទ
- ផ្សព្វផ្សាយបច្ចេកទេស ជំរុញ និងលើកទឹកចិត្តលើកាអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ។

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រីក្នុងបែ | ១០ គ្រួសារ ស្មើនឹង ១០បែ (១គ្រួសា=១បែ) | ត្រីប្រា | ២០០០០កូនត្រី | ខែសីហា ២០០៨ | ខែសីហា ២០១០ |

## គ.៥-ផែនការបោះបង្គោលព្រំប្រទល់សហគមន៍

**គោលបំណង**

- ងាយស្រួលក្នុងការគ្រប់គ្រង និងសហគមន៍ត្រូវតែមានព្រំប្រទល់ច្បាស់លាស់

- កាត់បន្ថយទំនាស់នេសាទនៅក្នុងតំបន់គ្រប់គ្រង

- ផ្សព្វផ្សាយដល់សាធារណៈជនទូទៅឱ្យបានដឹងពីទំហំ និងព្រំប្រទល់កន្លែងនេសាទដែលគ្រប់គ្រងដោយសន.។

| ចំនួនបង្គោល | ចំណុចត្រូវបោះ | អ្នកទទួលខុសត្រូវ | ពេលវេលា | | ផ្សេងៗ |
|---|---|---|---|---|---|
| | | | ចាប់ផ្តើម | បញ្ចប់ | |
| ១០បង្គោល (PIU) | តាមចំណុចក្នុងផែនទីសហគមន៍នេសាទ | គណៈកម្មការសហគមន៍នេសាទ | ខែកក្កដា ២០០៨ | ខែតុលា ២០០៨ | ត្រូវការជំនួយថវិកា និងការសហការពីស្ថាប័នជំនាញ និងអង្គការនានា |

## ត.៦ ផែនការទ្រទ្រង់ជីវភាព និងបង្កើនមុខរបរបស់សមាជិកសហគមន៍

### គោលបំណង

- បង្កើនប្រាក់ចំណូល និងកែលំអជីវភាពសមាជិកសន.

- សមាជិកសហគមន៍បានយល់ដឹងពីបច្ចេកទេសចិញ្ចឹមសត្វ

- ពង្រឹងសហគមន៍ និងបង្កើនការចូលរួមនៅក្នុងសន.។

| ប្រភេទកម្មវិធី | ចំនួន | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| ចិញ្ចឹមមាន់ និងជ្រូក | -មាន់ចំនួន ១០០ក្បាល ស្មើនឹង ១០គ្រួសារ (១គ្រួសារ=១០ក្បាល)<br>-ជ្រូកចំនួន ១៥០ក្បាល ស្មើនឹង ៣០ | -រៀបចំក្រុមចិញ្ចឹមសត្វ<br>-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ<br>-អនុវត្ត និងតាមដានការចិញ្ចឹមសត្វ | ២០០៨ | ២០១០ | រកដៃគូ NGOs និងរដ្ឋាភិបាលជួយ (ថវិកានិងបច្ចេកទេស) |

| | | | | | |
|---|---|---|---|---|---|
| | គ្រួសារ (១គ្រួសារ=៥ក្បាល) | | | | |
| កែច្នៃផលនេសាទ (ត្រីងៀត ផ្អក ប្រហុក មាំ ត្រីឆ្អើរ និងផ្សេងៗ) | ចំនួន ០១ក្រុម ស្មើនឹង ១០នាក់ | -ចងក្រងជាក្រុម<br>-បណ្តុះបណ្តាលបច្ចេកទេស (អ្នកចេះបង្ហាត់អ្នកមិនចេះ) ពួអញ្ជើញអ្នកបណ្តុះបណ្តាលពីខាងក្រៅ)<br>-អនុវត្តសកម្មភាពតាមដាន និងត្រួតពិនិត្យ | ២០០៨ | ២០១០ | រកដៃគូ NGOs និង រដ្ឋាភិបាលជួយ( ថវិកានិងបច្ចេកទេស) |

## គ.៧ ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

**គោលបំណង**

- បង្កើនសមត្ថភាពគណៈកម្មការសហគមន៍នេសាទ
- ពង្រឹងសហគមន៍នេសាទ
- មានសាមគ្គីភាព និងទំនាក់ទំនងល្អ

| ផែនការ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ ប្រមូលផល | ផ្សេងៗ |
|---|---|---|---|---|
| ពង្រឹងចំណេះដឹងផ្នែករដ្ឋបាល និងការគ្រប់គ្រងសន. | បណ្តុះបណ្តាលៈ<br>-ការធ្វើកំណត់ហេតុ និងរបៀបសរសេរខិតរដ្ឋបាល<br>-ការសរសេររបាយការណ៍គ្រប់សកម្មភាពការងារ និងការរាយការណ៍<br>-រៀបចំទុកដាក់ឯកសារសហគមន៍ និងរបៀបកត់ត្រាប្រចាំថ្ងៃ<br>- របៀបដោះស្រាយទំនាស់<br>- របៀបសរសេរគម្រោងស្នើសុំថវិកា | ២០០៨ | ២០០៨ | សុំជំនួយពី -ស្ថាប័នជំនាញ និងអ្នកសម្របសម្រួល<br>-អង្គការនានា |

| | | | | |
|---|---|---|---|---|
| ទស្សនៈកិច្ចសិក្សារផ្លាស់ប្តូរបទពិសោធន៍ | -ធ្វើទស្សនៈកិច្ចសិក្សារផ្លាស់ប្តូរបទពិសោធន៍រវាងសហគមន៍ និងសហគមន៍នៅក្នុងខេត្ត (០១ឆ្នាំម្តង)<br>-ធ្វើទស្សនៈកិច្ចសិក្សារផ្លាស់ប្តូរបទពិសោធន៍រវាងសហគមន៍ និងសហគមន៍ ក្រៅ ខេត្ត (៣ឆ្នាំម្តង) | ២០០៨ | ២០១០ | ស្នើសុំជំនួយពីអង្គការនានា |

## ត.៤ ផែនការល្បាត និងឃ្លាំមើលបទល្មើសនេសាទក្នុងដែនសន.

**គោលបំណង**

- ពង្រឹងសហគមន៍នេសាទ
- កាត់បន្ថយបទល្មើសនេសាទក្នុងកន្លែងនេសាទសន.
- ទទួលបានព័ត៌ទាន់ពេលវេលា

| **ផែនការ** | **សកម្មភាព** | **ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម** | **ថ្ងៃ ខែ ឆ្នាំ ប្រមូលផល** | **ផ្សេងៗ** |
|---|---|---|---|---|
| ការរៀបចំក្រុមល្បាត | -ចងក្រងក្រុមល្បាត និងឃ្លាំមើលដែននេសាទសន.<br>-រៀបចំផែនការល្បាត និងមានអ្នកទទួលខុសត្រូវច្បាស់លាស់<br>-សង់រោងយាមល្បាត ឬស្នាក់ការសន. សម្ភារៈ និងមធ្យោបាយល្បាត (ទូក កាណូត ម៉ាស៊ីនថតរូប វិទ្យុទាក់ទង បង្គោលក្រាក់បោះព្រំព្រែអភិរក្ស និងតំបន់អភិរក្សត្រីមេពូជ) | ២០០៨ | ២០១០ | -គណៈកម្មការសន.<br>-ជំនួយពីរដ្ឋាភិបាល ឬអង្គការនានា |

## ត.៥ ផែនការផ្សព្វផ្សាយ និងបង្កើតការយល់ដឹង

**គោលបំណង**

- ពង្រឹងសហគមន៍នេសាទ
- បង្កើនការយល់ដឹងរបស់សមាជិកសហគមន៍ និងអ្នកពាក់ព័ន្ធ
- កាត់បន្ថយបទល្មើសនេសាទនៅក្នុងសហគមន៍នេសាទ។

| ផែនការ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ ប្រមូលផល | ផ្សេងៗ |
|---|---|---|---|---|
| ផ្សព្វផ្សាយ និងបង្កើនការយល់ដឹង | លក្ខន្តិកៈនិង បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | ២០០៨ | ២០០៨ | គណៈកម្មការសន. និងអ្នកសម្របសម្រួល |
| | សារៈប្រយោជន៍នៃធនធានធម្មជាតិ និងបរិស្ថាន | ២០០៨ | ២០០៨ | |
| | ផែនទី កំណត់ព្រំប្រទល់កន្លែងនេសាទ | ២០០៨ | ២០០៨ | |
| | ផែនការគ្រប់គ្រងកន្លែងនេសាទ | ២០០៨ | ២០០៨ | |
| | ច្បាប់ជលផល និងច្បាប់ផ្សេងៗទាក់ទងដល់ការគ្រប់គ្រងសហគមន៍នេសាទ | ២០០៨ | ២០១០ | |
| | ការគ្រប់គ្រង និងសារៈប្រយោជន៍នៃព្រៃលិចទឹក | ២០០៨ | ២០០៨ | |

## គ-១០ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

**គោលបំណង**

- ពង្រឹងសហគមន៍នេសាទ
- ទទួលបានការគាំទ្រដល់សហគមន៍នេសាទ
- អភិវឌ្ឍសហគមន៍ និងបង្ហាញឱ្យគេឃើញពីឆន្ទៈរបស់សហគមន៍នេសាទមូលដ្ឋាន។

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | គណៈកម្មការចុះប្រមូលប្រាក់សមាជិកភាព | ២០០៨ | ២០០៨ | | |
| ភាគទានប្រចាំឆ្នាំ | គណៈកម្មការចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | ២០០៨ | ២០១០ | | |
| ជំនួយសប្បុរសជន និងអង្គការនានា | -សរសេគម្រោងស្នើសុំ<br>-ផ្សព្វផ្សាយអោយគេដឹងនូវសមិទ្ធិផលរបស់សហគមន៍ | ២០០៨ | ២០១០ | | |

| | | | | | |
|---|---|---|---|---|---|
| | និងតំបន់ដែលគួរជាទីទស្សនា<br>- ធ្វើហិបប្រាក់ភាគទាន<br>ទ្រទ្រង់សហគមន៍នេសាទ | | | | |
| បដិភាគរបស់រដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ឃុំ សង្កាត់ | -បញ្ចូលផែនការអភិវឌ្ឍន៍សហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ<br>-ស្នើសុំប្រាក់បដិភាគពីឃុំដើម្បីអនុវត្តផែនការសហគមន៍នេសាទ | ២០០៨ | ២០១០ | | |

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៍ និងចំណេះដឹងល្អៗ ជាពិសេសអំពីបញ្ហានេសាទ ។
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈ ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម ។
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ

- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ក្បាលស្ពឹង រយៈពេល ៣ ឆ្នាំ (២០០៧ ដល់ ២០១០)**

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ប្រើប្រាស់ឧបករណ៍នេសាទ | -កំណត់កន្លែងនេសាទ<br>-កំណត់ប្រភេទ និងទំហំ ឧបករណ៍នេសាទ និង ចំនួនមនុស្ស ដែលអាច ចូលនេសាទបានក្នុង ១ថ្ងៃ<br>-ផ្សព្វផ្សាយពីការកំណត់ ទំហំឧបករណ៍នេសាទ និងចំនួនមនុស្សដែល អនុញ្ញាតឱ្យចូលនេសាទ ក្នុងកន្លែងនេសាទនីមួយ ៗ ដល់សមាជិកសន. និងអ្នកមកពីខាងក្រៅ<br>-ចុះត្រួតពិនិត្យ តាមដាន ជាប្រចាំ។ | -ផលត្រីអាចកើនឡើង និងអាចកាត់បន្ថយបាន នូវការប្រើប្រាស់ឧបករណ៍ល្មើសច្បាប់ក្នុងដែន សន.<br>-អ្នកនេសាទនៅក្នុង កន្លែងសន.គ្រប់គ្រងនឹង អាចយល់ដឹងពីការគ្រប់ គ្រងរបស់សន. | -ចំណាយលើការត្រួត ពិនិត្យ និងតាមដាន ប្រមាណ ២០០០០០០ រៀល ក្នុង ១ឆ្នាំ<br>-ចំណាយលើការផ្សព្វ ផ្សាយ ១០០០០០ រៀល ក្នុង១ឆ្នាំ | -ភាគទានសន. និងសប្បុរសជន<br>-អង្គការនានា | ២០០៧ | ២០១០ | |
| ២-កែលំអរដែននេសាទ (អូរស្ពានស្រស់១,៦២ ហិកតា) | -ផ្សព្វផ្សាយពីការ កែលំអរ<br>-ជួលម៉ាស៊ីនបូមដី | -កន្លែងនេសាទមាន ជំរៅជ្រៅ ត្រីអាចធ្វើ ចរាចរបាន<br>-ផលត្រីកើនឡើង | ថ្លៃឈ្នួលគ្រឿងចក្រ ៥០០០$ | | ២០០៩ | ២០០៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣. កំណត់និងរៀបចំកន្លែងអភិរក្ស | -កំណត់កន្លែងអភិរក្ស និងបោះបង្គោលកំណត់ព្រំប្រទល់<br>-បោះស្លាកសញ្ញា និងការហាមឃាត់<br>-ផ្សព្វផ្សាយកន្លែងអភិរក្ស<br>-ដាក់ជំរកសប្បនិម្មិត | -កន្លែងអភិរក្សត្រីពូជ ចំនួន ១កន្លែងទំហំ ៧.១៩ ហិកតា និងព្រៃ អភិរក្ស ២កន្លែង នឹង (២៩.៧០ហត.)<br>-កន្លែងអភិរក្សទាំងអស់នឹងត្រូវបានបោះបង្គោលកំណត់ព្រំប្រទល់ និងស្លាកសញ្ញាហាមឃាត់បានត្រឹមត្រូវ<br>-ត្រី និងសត្វគ្រប់ប្រភេទនៅក្នុងតំបន់នោះនឹងសម្បូរឡើងវិញ ។ | -បោះបង្គោលព្រំប្រទល់ និងស្លាកសញ្ញា ១.០០០.០០០ រៀល<br>-ជំរកសប្បនិម្មិត ១.០០០.០០០ រៀល<br>-ផ្សព្វផ្សាយ និងយាមល្បាត ៨០០០០០ រៀល ក្នុង១ឆ្នាំ។ | -រដ្ឋាភិបាល<br>-អង្គការនានា<br>-សម្បុរសជន | ២០០៨ | ២០១០ | |
| ៤. ការគ្រប់គ្រង និងថែរក្សាព្រៃលិចទឹក | -ដាំព្រៃលិចទឹកទំហំ ១.៩៥ហិកតា នៅចំណុចប៉ោយតាមិញ និងចំការតាសាត<br>-ដាក់ស្លាកសញ្ញាហាមកាប់បំផ្លាញព្រៃលិចទឹក និងត្រួតពិនិត្យឃ្លាំមើលជាប្រចាំ<br>-ផ្សព្វផ្សាយពីសារ | -គ្រប់គ្រងបានល្អ និងមានការចូលរួមផុសពីសន.<br>-មានព្រៃលិចទឹកល្អនៅក្នុងតំបន់គ្រប់គ្រងដោយសហគមន៍ នឹងសម្បូរត្រីឡើងវិញ ជីវភាពប្រជាជននឹងបានធូរធា។ | ១.០០០.០០០ រៀល ក្នុង១ឆ្នាំ | -សហគមន៍នេសាទ<br>-រដ្ឋាភិបាល<br>-អង្គការនានា | ២០០៨ | ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ប្រយោជន៍នៃព្រៃលិចទឹកជាសាធារណៈ។<br>-បែងចែកតួនាទី និងការទទួលខុសត្រូវក្នុងការការពារ ថែរក្សាព្រៃលិចទឹក។ | | | | | | |
| ៥-អភិវឌ្ឍន៍វារីវប្បកម្ម<br>-ត្រីដីរី៧គ្រួសារ<br>-ក្រពើក្នុងបែ១៥គ្រួសារ<br>-ក្រពើក្នុងអាង១៥គ្រួសារ<br>-ជីកស្រះ ៦គ្រួសារ<br>-ត្រីអណ្ដែង១០គ្រួសារ | -ចងក្រងក្រុមអ្នកចិញ្ចឹមត្រី<br>-ផ្សព្វផ្សាយបច្ចេកទេសពីការចិញ្ចឹមត្រីក្នុងបែដល់សមាជិកសន.<br>-ត្រួតពិនិត្យ និងតាមដាន | -បង្កើនប្រាក់ចំណូលគ្រួសារដល់សមាជិកសន | -ចំណាយលើការផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលបច្ចេកទេស ២០០០០០រៀល ក្នុង១ឆ្នាំ<br>-ប៉ាន់ប្រមាណលើការសាងសង់ និងដាក់ពូជចិញ្ចឹម ១០.០០០.០០០រៀល<br>-សហគមន៍ទទួលខុសត្រូវទាំងស្រុងលើការចិញ្ចឹម | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សហគមន៍នេសាទ | ២០០៨ | ២០១០ | |
| ៦- បោះបង្គោលព្រំប្រទល់សហគមន៍នេសាទ | -រៀបចំក្រុមទទួលខុសត្រូវ និងចាត់ចែងបោះបង្គោលសន.<br>-សហការជាមួយក្រុមបច្ចេកទេសផែនទី | -បង្គោលចំនួន១០ដើមនឹងត្រូវបានគេបោះជាព្រំប្រទល់សន.<br>-កាត់បន្ថយបាននូវទំនាស់ព្រំប្រទល់សន. | -ចំណាយសរុប ២៥០០០០០រៀល | -រដ្ឋកិបាល<br>-អង្គការនានា | ខែកក្កដា ២០០៨ | ខែតុលា ២០០៨ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | និងអ្នកសម្របសម្រួល ដើម្បីបោះបង្គោលសន. ឱ្យចំទៅតាមចំណុចដែលមាននិយាមកាត្រឹមត្រូវ នៅលើផែនទីសន. និងយុទ្ធនាការបោះបង្គោល<br>-ផ្សព្វផ្សាយពីព្រំប្រទល់សន.ជាសាធារណៈ ។ | -កាត់បន្ថយបានការល្មើសនេសាទនៅក្នុងកន្លែងនេសាទសន. និងគ្រប់គ្រងកន្លែងនេសាទសន.បានល្អ ។ | | | | | |
| ៧- ទ្រទ្រង់ជីវភាព និងបង្កើនមុខរបរដល់សមាជិកសហគមន៍នេសាទ<br>-ចិញ្ចឹមទា២០គ្រួសារ<br>-ចិញ្ចឹមមាន់២០គ្រួសារ<br>-ចិញ្ចឹមជ្រូក១០គ្រួសារ<br>-បណ្តុះផ្សិត២០គ្រួសារ<br>-ចិញ្ចឹមជន្លេន២០គ្រួ.<br>-ក្រងស្បូវ២០គ្រួសារ<br>-សន្សំប្រាក់១០គ្រួសារ | -ជ្រើសរើសកសិករគំរូ និងបង្កើតក្រុម<br>-បណ្តុះបណ្តាលបច្ចេកទេស<br>-ផ្តល់ពូជតាមគ្រួសារ<br>-រៀបចំទ្រុង ធ្វើរង រោងជន្លេន និងធ្វើរោងសិប្បកម្មក្រងស្បូវ | -សមាជិកសន.ប្រមាណ ៣០% អាចបង្កើនប្រាក់ចំណូលតាមរយៈសកម្មភាពចិញ្ចឹមសត្វ និងអាចចេះដឹងពីបច្ចេកទេសចិញ្ចឹមសត្វ និងការដាំដុះ | -ចំណាយសរុបប្រមាណ ២.០០០.០០០ រៀល សម្រាប់ការបណ្តុះបណ្តាល<br>-១៥០.០០០ រៀល សម្រាប់ការផ្សព្វផ្សាយ និងតាមដាន<br>-១.០០០.០០០រៀល<br>-សម្រាប់ពូជ និងបង្កើតទីតាំងចិញ្ចឹម ។ | -រដ្ឋាភិបាល<br>-អង្គការនានា | ២០០៨ | ២០១០ | |
| ៧-ពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ | -បណ្តុះបណ្តាលចំណេះដឹងផ្នែករដ្ឋបាល | -គណៈកម្មការសន.នឹងយល់ដឹងពីរបៀបរៀបចំ | -ការចំណាយលើការបណ្តុះបណ្តាល ផ្សព្វផ្សាយ | -រដ្ឋាភិបាល<br>-អង្គការនានា | ២០០៨ | ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | និងការគ្រប់គ្រងសន. (របៀបធ្វើកំណត់ហេតុ សរសេររបាយការណ៍ ការកត់ត្រា និងការរៀបចំទុកដាក់ឯកសារសន. របៀបដោះស្រាយទំនាស់ និងការសរសេរគម្រោងស្នើសុំថវិកា)<br>-ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | ទុកដាក់ឯកសារសន. ចេះសរសេររបាយការណ៍ កំណត់ហេតុ និងលិខិតស្នាមផ្សេងៗ<br>-គណៈកម្មការសន.នឹងចេះដោះស្រាយទំនាស់នៅក្នុងសន. មានជំនាញសម្របសម្រួល និងចេះសរសេរសំណើស្នើសុំថវិកា<br>-សន.នឹងអាចផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមករវាងសន. និងសន.ក្នុងការអនុវត្តគ្រងគ្រងសន.។ | និងត្រួតពិនិត្យ ២.០០០.០០០ រៀល<br>-ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ ២.០០០.០០០ រៀល | -សម្ព័ន្ធសជន | | | |
| ៨-ពង្រឹងការល្បាត និងឃ្លាំមើលបទល្មើសនេសាទក្នុងកន្លែងនេសាទសន. | -រៀបចំក្រុម និងធ្វើផែនការល្បាត<br>-រៀបចំរោងយាមល្បាត សម្ភារៈ និងមធ្យោបាយល្បាត<br>-រៀបចំបណ្តាញសន. | -បទល្មើសនេសាទក្នុងកន្លែងនេសាទសន. នឹងកាត់បន្ថយបាន៧០%<br>-នឹងកាត់បន្ថយបាននូវការទំនាស់នេសាទក្នុងដែននេសាទសន. | -ចំណាយប្រមាណ ១.០០០.០០០៛ ទៅលើការល្បាត ក្នុង១ឆ្នាំ<br>-ចំណាយប្រមាណ ២.០០០ ដុល្លា លើការសាងសង់រោងយាមល្បាត | -រដ្ឋាភិបាល<br>-អង្គការនានា<br>-សម្ព័ន្ធសជន | ២០០៨ | ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | -បណ្តុះបណ្តាលពីការល្បាត និងតួនាទីបណ្តាញ | -នឹងទទួលបានព័ត៌មានឆាប់រហ័ស និងមានការសហការល្អ | ស្នាក់ការសន. ទូកល្បាត២ កាណូត ៣០សេះ វិទ្យុទាក់ទង ២គ្រឿង និង បោះបង្គោលក្រាក់ជុំវិញតំបន់ព្រៃការពារ និងតំបន់អភិរក្សត្រីមេពូជ | | | | |
| ៩-ផ្សព្វផ្សាយ បណ្តុះបណ្តាល បង្កើនការយល់ដឹង | ផ្សព្វផ្សាយ<br>-លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសន.<br>-សារៈប្រយោជន៍ព្រៃលិចទឹក<br>-ធនធានធម្មជាតិ និងបរិស្ថាន<br>-ព្រំប្រទល់កន្លែងនេសាទសន. និង ផែនទី<br>-ច្បាប់ផ្សេង១ទាក់ទងនឹងការគ្រប់គ្រងសន.<br>-ផលប៉ះពាល់នៃការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ ។ | -សមាជិកសហគមន៍ប្រមាណពី ៧០-៨០% យល់ដឹងពីការគ្រប់គ្រងសន. លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ច្បាប់ជលផល និងច្បាប់ផ្សេង១ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន | -ចំណាយសរុប ១០០០០០០ រៀល ក្នុង ១ឆ្នាំ | -រដ្ឋាភិបាល<br>-អង្គការនានា | ២០០៨ | ២០០៩ | |
| ១០-ថវិកាទ្រទ្រង់សម្រាប់ | -ប្រមូលភាគទាន | -សមាជិកសន.១០០% | ៥០០០០០ រៀល | -រដ្ឋាភិបាល | ២០០៨ | ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| អភិវឌ្ឍន៍សហគមន៍ | សមាជិកសន.<br>-ប្រមូលភាគទានប្រចាំឆ្នាំ<br>-ស្វែងរកថវិកាពីរដ្ឋាភិបាល សម្បុរសជន និងអង្គការនានា | បានបង់ប្រាក់សមាជិកភាព<br>-ប្រមាណ ៨០% នៃអ្នកដែលពាក់ព័ន្ធនឹងដែននេសាទសន. នឹងត្រូវបានប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ<br>-ថវិកាមួយចំនួននឹងត្រូវបានផ្តល់សម្រាប់ទ្រទ្រង់សន.ដោយអង្គការនានា រដ្ឋាភិបាល និងសម្បុរសជន<br>-ទឹកប្រាក់ប្រមាណ ១.០០០.០០០ រៀល នឹងត្រូវប្រមូលបានពីការប្រមូលភាគទានក្នុង ១ឆ្នាំ។ | សម្រាប់ការអនុវត្ត និងផ្សព្វផ្សាយ | -អង្គការនានា<br>-សម្បុរសជន<br>-សមាជិកសន. និងអ្នកពាក់ព័ន្ធ | | | |

| សកម្មភាព | ២០០៨ | | | | | | | | | | | | ២០០៩ | | | | | | | | | | | | ២០១០ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| **១. ការប្រើប្រាស់ឧបករណ៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១.១.កំណត់កន្លែងនេសាទ ប្រភេទ និងទំហំ ឧបករណ៍នេសាទនិងចំនួនមនុស្ស ដែលអាចចូល នេសាទ បានក្នុង១ថ្ងៃ | ■ | ■ | ■ | ■ | ■ | | | | | | | | ■ | ■ | ■ | ■ | ■ | | | | | | | | ■ | ■ | ■ | ■ | ■ | | | | | | | |
| ១.២ ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | | | | | | | ■ | ■ | ■ | ■ | ■ | ■ | | | | | | | ■ | ■ | ■ | ■ | ■ | ■ | | | | | | | ■ | ■ | ■ | ■ | ■ | ■ |
| ១.៣. ត្រួតពិនិត្យតាមដាន | ■ | ■ | ■ | ■ | ■ | ■ | | | | | | | ■ | ■ | ■ | ■ | ■ | ■ | | | | | | | ■ | ■ | ■ | ■ | ■ | ■ | | | | | | |
| **២.ការកែលំអរដែននេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.១ ស្តារព្រែកអន្លងអភិរក្សអូរស្អានស្រស់ទំហំ១.៦២ ហិកតា | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | |
| ២.២ ជួលម៉ាស៊ីនបូមដី | | | | | | | | | | | | | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | |
| **៣.កំណត់ និងរៀបចំកន្លែងអភិរក្ស** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.១. កំណត់កន្លែងអភិរក្ស និងបោះបង្គោលព្រំប្រទល់ ( អន្លង់អភិរក្សត្រីពូជ ១កន្លែង និងព្រែកអភិរក្ស២កន្លែង) | | | | | | | | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | |
| ៣.២. បោះស្លាកសញ្ញាហាមឃាត់ | | | | | | | | | | | | ■ | | | | | | | | | | | | | | | | | | | | | | | | |
| ៣.៣.ផ្សព្វផ្សាយ | | | | | | | | | | | | | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | |
| ៣.៤.ដាក់ជំរកសប្បនិម្មិត | | | | | | | | | | | | | | | | | | | | | | ■ | ■ | ■ | | | | | | | | | | | | |
| ៣.៥.យាមល្បាត និងតាមដានជាប្រចាំ | | | | | | | | | | | | | | | | | ■ | ■ | | | | | | | | | | | | | | | | | | |
| **៤.ការគ្រប់គ្រងព្រៃលិចទឹក** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 | 31 | 32 | 33 | 34 | 35 | 36 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៤.១.ដាំព្រៃលិចទឹកឡើងវិញ២កន្លែង ទំហំ១,៩៩ ហិកតា | | | | | | | | | | | X | X | | | | | | | | | | | | | | | | | | | | | | | | |
| ៤.១.បោះស្លាកសញ្ញាហាមឃាត់ | | | | | | | | | | | | | X | X | | | | | | | | | | | | | | | | | | | | | | |
| ៤.២.ផ្សព្វផ្សាយ | | | | | | | | | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | |
| ៤.៣.ត្រួតពិនិត្យ ថែរក្សា តាមដាន និងឃ្លាំមើលជាប្រចាំ | | | | | | | | | | | | | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| **៥.ការអភិវឌ្ឍន៍វារីវប្បកម្ម** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥.១.ចងក្រងក្រុមចិញ្ចឹមត្រី . ក្រពើ | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥.២.បណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រី ក្រពើ | | | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥.៣. អនុវត្តការចិញ្ចឹមតាមអាង និងតាមបែ | | | | | | | | X | X | X | X | X | | | X | X | X | X | X | X | X | X | | | X | X | X | X | X | X | X | X | X | X | X | X |
| ៥.៤.ត្រួតពិនិត្យ តាមដាន | | | | | | | | | | | | | X | X | X | X | X | X | X | X | X | X | X | X | | | | | X | X | X | X | X | X | X | X |
| **៦.បោះបង្គោលព្រំប្រទល់សន** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.១.រៀបចំក្រុមទទួលខុសត្រូវ និងចាត់ចែងការបោះបង្គោល | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.២.យុទ្ធនាការបោះបង្គោលចំនួន១០ បង្គោល | | | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.៣.ផ្សព្វផ្សាយជាសាធារណៈ | | | | | | | | | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | |
| **៧. ទ្រទ្រង់ជីវភាពនិងបង្កើនមុខរបរដល់សមាជិកសន.** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.១.បង្កើត និងចងក្រងក្រុមចិញ្ចឹមមាន់ ទា ជ្រូក ដាំបន្លែ បណ្តុះផ្សិត ក្រងស្បូវ និងក្រុមសន្សំប្រាក់ | | | | | | | | | | X | X | X | | | | | | | | | | | | | | | | | | | | | | | | |
| ៧.២.បណ្តុះបណ្តាលបច្ចេកទេសស្តីពី ការចិញ្ចឹមសត្វ និងការកែច្នៃផល នេសាទ | | | | | | | | | | | | | X | X | X | X | X | | | | | | | | | | | | | | | | | | | |
| ៧.៣. អនុវត្តសកម្មភាពចិញ្ចឹមមាន់ និងជ្រូក និងការកែច្នៃផលនេសាទ | | | | | | | | | | X | X | X | | | X | X | X | X | X | X | X | X | X | X | | | | | | | | | | | | |

| សកម្មភាព | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៧.៤. តាមដានការអនុវត្តន៍សកម្មភាព និងផ្សព្វផ្សាយ | | | | | | | | | | | | | | | | | | | | | | | | | X | X | X | X | X | X | | | | | | |
| **៨. ពង្រឹងសមត្ថភាពគណៈកម្មការសន.** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៨.១.បណ្តុះបណ្តាលចំណេះដឹងផ្នែករដ្ឋបាល (របៀបសរសេរកំណត់ហេតុ របាយការណ៍ ការកត់ត្រា និងរបៀបរៀបចំទុកដាក់ឯកសារសន.) | | | | | | | | X | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | |
| ៨.២.បណ្តុះបណ្តាលចំណេះដឹងផ្នែកគ្រប់គ្រងសន. (របៀបដោះស្រាយទំនាស់ និងការសរសេរគម្រោងស្នើសុំថវិកា) | | | | X | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៨.៣.រៀបចំទស្សនៈកិច្ចសិក្សា | | | | | | | | | | | | | | | | | | | | | X | X | X | X | | | | | | | | | | | | |
| **៩. ពង្រឹងការល្បាត និងឃ្លាំមើលបទល្មើសនេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩.១. រៀបចំក្រុមល្បាត និងធ្វើផែនការល្បាត | | | | | | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ៩.២. សង់រោងយាមល្បាត ឬស្លាក់ការសន. រៀបចំសម្ភារៈល្បាត និង មធ្យោបាយល្បាត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩.៣. បណ្តុះបណ្តាលក្រុមល្បាត | | | | | | | | X | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | |
| **១០.ផ្សព្វផ្សាយ និងបង្កើនការយល់ដឹង** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១០.១.ផ្សព្វផ្សាយពីការងារគ្រប់គ្រងសន. (លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ព្រំប្រទល់កន្លែងនេសាទសន.) | | | | | | | | | | X | X | X | X | X | X | X | X | X | X | X | X | X | X | X | | | | | | | | | | | | |
| ១០.២. ផ្សព្វផ្សាយ និងបង្កើនការយល់ដឹង (សារៈប្រយោជន៍ព្រៃលិចទឹក ផលប៉ះពាល់បរិស្ថាន ផលប៉ះពាល់នៃការប្រើប្រាស់ឧបករណ៍នេសាទ ខុសច្បាប់ និងច្បាប់ផ្សេងៗ ទាក់ទងនឹងការគ្រប់គ្រងសន.) | | | | | | | X | X | X | X | X | X | | | | | | | X | X | X | X | X | X | | | | | | | X | X | X | X | X | X |
| **១១. ពង្រឹងល្បាត និងឃ្លាំមើលបទល្មើសនេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១១.១.រៀបចំក្រុមល្បាតនិងធ្វើផែនការល្បាត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១១.២. សង់រោងយាមល្បាត ឬស្លាក់ការសន. រៀបចំសម្ភារៈល្បាត និង មធ្យោបាយល្បាត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១១.៣. បណ្តុះបណ្តាលក្រុមល្បាត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **១២.ថវិកាទ្រទ្រង់សហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១២.១.ប្រមូលភាគទានសមាជិកភាព | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១២.២.ប្រមូលភាគទានប្រចាំឆ្នាំ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១២.៣.ការស្វែងរកថវិកា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

បានឃើញ និងបញ្ជូនមក
លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ
" ដើម្បីសូមមេត្តាពិនិត្យ-សំរួល "
ស្ទោងថ្ងៃទី ...២៥.....ខែ កក្កដា ឆ្នាំ ២០០៨
**រាយសង្កាត់រដ្ឋបាលជលផល ស្រុកស្ទោង**

គន-ចាន់សីហា

បានឃើញ
កំពង់ចិន....ថ្ងៃទី ..១៧... ខែកក... ឆ្នាំ ២០០៨
មេឃុំ កំពង់ចិនត្បូង

ឈុន-ឆាត

ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨
**ប្រធានគណៈកម្មការសហគមន៍នេសាទ**

គត ខែ

លេខ: [illegible]

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ,ថ្ងៃទី២៧...ខែ[illegible]...ឆ្នាំ ២០០៨

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**ណៅ_ធូក**

លេខ: ១៣៥...អ.រ.ជ

បានឃើញ និងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា

ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

"ដើម្បីសូមមេត្តាពិនិត្យ-សម្រេចដោយអនុគ្រោះ"

**នាយអធិការដ្ឋានរដ្ឋបាលជលផលខាងជើងបឹងទន្លេសាប**

**ថាន់ ឋាន់ធី**

លេខ: ១៤៧...ខរជ.កធ

បានឃើញ និងគោរពជូន

ឯកឧត្តមនាយអធិការដ្ឋានរដ្ឋបាលជលផលខាងជើងបឹងទន្លេសាប

"ដើម្បីសូមមេត្តាពិនិត្យ-សំរួល"

កំពង់ធំ, ថ្ងៃទី[illegible]...ខែ[illegible]...ឆ្នាំ ២០០៨

**នាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ**

**ឯក_ហេង**